ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៣៥/០៩ — ៣ ឃ្យូ ហ្គាមិន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈើរ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ខូអិលធីឌី**

អាសយដ្ឋាន : ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៤៥៦ ២២៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- កញ្ញា ពឹង ហ្គេចតី អ្នកបកប្រែ

២- លោក ស៊ាវ គីមឆាយ តំណាងក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធបជីព-សហជីព ការងារកម្មករកម្ពុជា នៃរោងចក្រកាត់ដេរ ៣ ឃ្យូ ហ្គាមិន**

អាសយដ្ឋាន : ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៥៨ ០០៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

| | |
|---|---|
| ១- លោក ឈិន សុទី | អនុប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា |
| ២- លោក ឯក សុខដា | អគ្គលេខាសហព័ន្ធសហជីពការងារកម្មករកម្ពុជា |
| ៣- លោកស្រី គ្រីត ស្រីម៉ុម | ប្រធានក្រុមដេរ ៣ យូ |
| ៤- លោកស្រី យ៉ែម ល័ក្ខ | ផ្នែកដេរ ៣ យូ |
| ៥- លោកស្រី ថោង រិន | ផ្នែកដេរ ៣ យូ |
| ៦- លោកស្រី ឈាង លីដា | ផ្នែកដេរ ៣ យូ |
| ៧- លោកស្រី សែត ស៊ីម | ផ្នែកដេរ ៣ យូ |
| ៨- លោកស្រី គ្រីត សិទ្ធា | ផ្នែកដេរ ៣ យូ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិត ដែលធ្វើការនៅក្រុម B ចោទប្រកាន់ថា ក្រុមហ៊ុនបានបញ្ឈប់ពួកគាត់ពីការងារ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនបានបញ្ឈប់ពួកគាត់ពីការងារឡើយ មូលហេតុដែលពួកគាត់មិនព្រមចូលធ្វើការ គឺបងប្អូនទាំងអស់នោះ នៅតែទាមទារឱ្យក្រុមហ៊ុនរក្សាតួនាទីរបស់អ្នកស្រី គ្រីត ស្រីមុំ ជាប្រធានក្រុមដដែល។

២- កម្មករនិយោជិតនៅក្រុម B នៅតែទាមទារឱ្យក្រុមហ៊ុនរក្សាតួនាទីអ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម B នៅដដែល។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលអ្នកស្រី គ្រិត ស្រីមុំ ឱ្យធ្វើការជាប្រធានក្រុមបានឡើយ ព្រោះអ្នកស្រីពុំមានសមត្ថភាពធ្វើជាប្រធានក្រុមឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីសម្រេចនេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្ដីអំពីការមិនសះជា លេខ ១៧៨ ក.ប./អក/វ.ក ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩។

**សវនាការ និង សន្ទនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានីតិវិធី :**

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់សហព័ន្ធសហជីព ការងារកម្មករកម្ពុជា លើករណីទាមទារឱ្យក្រុមហ៊ុនរក្សាតួនាទីជាប្រធានក្រុម បេ ឱ្យនៅដដែល។ បន្ទាប់មក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយ និងផ្សះផ្សាជាបន្តបន្ទាប់ និងផ្សះផ្សាចុងក្រោយ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០២ ចំណុច ។

ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ តាមរបាយការណ៍ស្ដីពីវិវាទការងាររួមមិនសះជា លេខ ១៧៨ ក.ប/អ.ក/វ.ក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញ ភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ០២:០០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់អាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានព្យាយាម សួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជា ទាំង ០២ ចំណុចបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹង ធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ជូន កញ្ញា ពីង ហ្គេចតី ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ខូអិលធីឌី ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩។

២- កំណត់ហេតុស្ដីពី ការសាកសួរពត៌មានពីតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩។

៣- ពាក្យបណ្ដឹងរបស់កម្មករនិយោជិត ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩។

៤- លិខិតពឹងពាក់របស់កម្មករនិយោជិត ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ខូអិលធីឌី លេខ ១៧៨ ក.ប./អក/វ.ក ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ខូអិលធីឌី ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៦២ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៦១ កប/អក/វក/លកអ. ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩។

**អង្គហេតុ**

-ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

-ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

-ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា :**

- ក្រុមហ៊ុន ៣ ឃ្យូ ហ្គាមិន ខូអិលធីឌី មានអាសយដ្ឋាននៅភ្នំពេញ និងមានកម្មករនិយោជិតចំនួន ១៤០ នាក់។ នៅក្នុងក្រុមហ៊ុននេះ ពុំទាន់មានវត្តមានសហជីពណាមួយនៅឡើយទេ។

- នៅក្នុងសំណុំរឿងនេះមានកម្មករនិយោជិតចំនួន ១៣ នាក់ ដែលជាដើមបណ្តឹង ។
- កម្មករនិយោជិតទាំង ១៣ នាក់នេះ មានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
- អ្នកស្រី ក្រិត ស្រីមុំ បានចូលបំរើការងារ នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៧ ក្នុងតួនាទីជាអ្នកដេរ និងមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
- នៅដើមខែ កក្កដា ២០០៧ អ្នកស្រី ក្រិត ស្រីមុំ ត្រូវបានតំឡើងឋានៈជាប្រធានផ្នែកដេរនៃក្រុមបេ ហើយគ្រប់គ្រងកម្មករនិយោជិតផ្នែកដេរទាំងអស់ចំនួន ៣៦ នាក់។
- ក្នុងតួនាទី ជាប្រធានផ្នែកដេរ អ្នកស្រី ក្រិត ស្រីមុំ ទទួលនូវប្រាក់ឈ្នួលសរុបចំនួន ១៤៦ ដុល្លារអាមេរិក ក្នុងមួយ ខែ និងដែលមានការបែងចែក ដូចខាងក្រោម:
    - ប្រាក់ខែគោល ចំនួន ៨០ ដុល្លារអាមេរិក
    - ប្រាក់តួនាទី ចំនួន ៤០ ដុល្លារអាមេរិក
    - ប្រាក់រង្វាន់ ចំនួន ២០ ដុល្លារអាមេរិក
    - ប្រាក់ឧបត្ថម្ភជីវភាពចំនួន ៦ ដុល្លារអាមេរិក
- នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ នាយកក្រុមហ៊ុន បានហៅប្រធានក្រុម បេ ឈ្មោះ ក្រិត ស្រីមុំ អោយចូលទៅជួប និងដាក់ផែនការកំណត់ឱ្យក្រុម បេ ទាំងមូលដេរឱ្យបាន ១ថ្ងៃចំនួន ២៥០០។
- អ្នកស្រី ក្រិត ស្រីមុំ បានសុំឱ្យក្រុមហ៊ុនទុកពេលឱ្យក្រុមខ្លួនមួយអាទិត្យ ដើម្បីធ្វើការសាកល្បងដេរឱ្យបាននូវតួលេខ ដែលក្រុមហ៊ុនដាក់ឱ្យ។ ប៉ុន្តែក្រោយពេលសាកល្បងមួយអាទិត្យក្រោយមក ក្រុមរបស់ខ្លួនក៏មិនអាចធ្វើបានតាមចំនួនដែលក្រុមហ៊ុនកំណត់ អ្នកស្រីបាននិយាយសុំក្រុមហ៊ុន បន្ធូរបន្ថយតួលេខនេះ និងបាននិយាយថា នឹងព្យាយាមថែមទៀត ដើម្បីសម្រេចឱ្យបានតាមផែនការ។
- នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ អ្នកស្រី ក្រិត ស្រីមុំ បានឱ្យកម្មការនីដែលជាអ្នកដេរទាំងអស់ចេញទៅផ្ទះនៅម៉ោង ៥:១៥ នាទី នៅពេលដែលពួកគាត់ដេរបានចំនួន ២៣០០។ នៅក្នុងសវនាការ កម្មករនិយោជិត បានលើកឡើងថា ម៉ោងចេញធ្វើការធម្មតា គឺម៉ោង ០៤:០០ នាទី រសៀល ហើយបើក្នុងករណីមានការថែមម៉ោង គឺត្រូវចេញ នៅម៉ោង ០៦:០០ ល្ងាច។
- អ្នកស្រី ក្រិត ស្រីមុំ បានសម្រេចឱ្យកម្មការនីក្នុងក្រុមគាត់ចេញទៅផ្ទះវិញដោយចិត្តឯង និងដោយគ្មានការអនុញ្ញាតពីថ្នាក់លើណាមួយឡើយ។ អ្នកស្រី ក្រិត ស្រីមុំ បានលើកឡើងថា កូនក្រុមទាំងអស់ធ្វើការហត់នឿយច្រើនហើយក្នុងអាទិត្យកន្លងមក ម្យ៉ាងទៀតកម្មករនិយោជិតទាំងអស់នោះមិនធ្លាប់ដេរបាន ២៣០០ អាវទេ។ ថ្ងៃនេះជាលើកទី១ ដូច្នេះអ្វីដែលគាត់ម្រេចនេះ គឺជាការលើកទឹកចិត្តកូនក្រុមរបស់ខ្លួនផង និងម្យ៉ាងទៀតនៅក្នុងក្រុមហ៊ុនក៏អស់ឥវ៉ាន់សម្រាប់ដេរផងដែរ។

- នៅល្ងាចថ្ងៃដដែលនោះ ក្រោយពេលកូនក្រុមចេញអស់ អ្នកស្រី ក្រិត ស្រីមុំ ត្រូវបានប្រធានចិនហៅទៅណែនាំ ដោយសុំឱ្យគាត់ឈប់ធ្វើដូច្នេះតទៅទៀត បើក្នុងករណីអស់ឥវ៉ាន់ដេរក៏ត្រូវតែនៅកន្លែងធ្វើដដែលដែរ ព្រោះថា ក្រុមហ៊ុននឹងបង់ប្រាក់ជូនចំពោះម៉ោងបន្ថែម។
- ប្រធានក្រុមចិនបានផ្តល់ឱកាសឱ្យអ្នកស្រី ក្រិត ស្រីមុំ បន្តទៀតដោយឱ្យពេលគាត់បន្ថែមទៀត ដើម្បីឱ្យគាត់គ្រប់គ្រងកម្មការនីទាំង ៣៦ នាក់នោះ ដេរឱ្យបានសម្រេចចំនួន ២៥០០ អាវ ទៅតាមផែនការរបស់ក្រុមហ៊ុន។ លទ្ធផលនាថ្ងៃបន្តបន្ទាប់មកទៀតមានចំនួន ២០០០ អាវ និង តិចជាង ២០០០ អាវ។
- នៅថ្ងៃទី ២៧ ខែ កុម្ភៈ ២០០៩ នាពេលល្ងាច ប្រធានក្រុមចិនបានហៅអ្នកស្រី ក្រិត ស្រីមុំ មកប្រាប់ថា អ្នកស្រី ក្រិត ស្រីមុំ ធ្វើការជាប្រធានក្រុមទៅទៀតលែងបាន និងបានសម្រេចឱ្យអ្នកស្រី ក្រិត ស្រីមុំ មកធ្វើជាអ្នកដេរធម្មតាវិញ។ ការត្រឡប់មកធ្វើជាអ្នកដេរវិញ មានន័យថា អ្នកស្រីក្រិត ស្រីមុំ នឹងលែងមានសិទ្ធិទទួលបានប្រាក់តួនាទីចំនួន ៤០ ដុល្លារអាមេរិក និង ប្រាក់រង្វាន់ប្រធានក្រុម ២០ ដុល្លារអាមេរិក ទៀតហើយ។ ដូចនេះចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ នេះតទៅ លែងមានប្រធានក្រុមទៀតហើយ គឺប្រធានចិនគ្រប់គ្រងដោយផ្ទាល់។
- ក្នុងសវនការ ភាគីនិយោជកបានបញ្ជាក់ថា តាំងពីអ្នកស្រី ក្រិត ស្រីមុំ ធ្វើជាប្រធានក្រុមមក ក្រុមហ៊ុនមិនដែលធ្វើការព្រមានគាត់ទេ គ្រាន់តែធ្វើការណែនាំផ្ទាល់មាត់ ហើយទាក់ទងនឹងការដេរមិនគ្រប់ចំនួនកំណត់របស់ក្រុមហ៊ុននោះ ក្រុមហ៊ុនមិនដែលព្រមានគាត់ថា បើធ្វើមិនគ្រប់ចំនួន ២៥០០ អាវ នេះទេ នឹងត្រូវទំលាក់ពីតំណែងដែរ ប៉ុន្តែបានព្រមាននៅថ្ងៃទី ២៦ នោះឱ្យគាត់ដឹកនាំកម្មការនីដេរឱ្យបានគ្រប់ចំនួន ២៥០០អាវ ។
- នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ នៅពេលព្រឹក ប្រធានចិនបានមកគ្រប់គ្រងការងារដោយផ្ទាល់ ហើយបានចាត់ចែងអ្នកស្រី ក្រិត ស្រីមុំ មកជាកម្មការនីដេរធម្មតាវិញ។
- អ្នកស្រី ក្រិត ស្រីមុំ បានឆ្លើយតបថា គាត់មិនព្រមធ្វើជាកូនក្រុមដេរទេ គាត់គឺជាប្រធានក្រុម។ ពេលនោះកម្មការនីក្នុងក្រុម បេ ទាំងអស់ក៏មិនអនុវត្តន៍តាមការចាត់ចែងតាមការបញ្ជារបស់ប្រធានចិនដែរ ដោយក្រោកឈរទាំងអស់គ្នា ហើយផ្អាកការងាររបស់ខ្លួន។
- ភាគីនិយោជកបានអះអាងថា ដើម្បីកុំឱ្យរំខានដល់អ្នកដទៃធ្វើការ ប្រធានចិនបានស្នើឱ្យអ្នកដែលមិនព្រមដេរ ចេញពីកន្លែងដេរ។ ប្រធានចិនក៏ចែកប៉ុង និង ឱ្យចុះហត្ថលេខាលើប៉ុងរបស់កម្មការនីនៅក្រុម បេ ទាំងអស់ហើយ កម្មករនិយោជិតណាមិនព្រមចូលធ្វើការ អាចមកបើកប្រាក់ឈ្នួល និង ប្រាក់បំណាច់ប្រចាំឆ្នាំបាន។
- នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ នោះ កម្មការនីក្រុម បេ បានឈប់ធ្វើការ និងទាមទារឱ្យក្រុមហ៊ុនទទួលយក អ្នកស្រី ក្រិត ស្រីមុំ ជាមេក្រុមវិញ តែភាគីក្រុមហ៊ុនបានបដិសេធ។ ភាគីកម្មករនិយោជិត

បញ្ជាក់ថា ក្រោយពេលប្រធានក្រុមមិនចែកបុងឱ្យហើយប្រាប់ឱ្យទៅបើកប្រាក់ឈ្នួលចុងក្រោយ និង ប្រាក់បំណាច់ប្រចាំឆ្នាំ ព្រមទាំងប្រមូលកាតទៀត ដូច្នេះបានន័យថា ក្រុមហ៊ុនបញ្ឈប់ពួកគាត់មិនឱ្យធ្វើការ ហេតុនេះគាត់ទាមទារឱ្យក្រុមហ៊ុនទទួលពួកគាត់ចូលធ្វើការវិញ ហើយបើមិនយកចូលវិញទេ សូមឱ្យក្រុមហ៊ុនគិតប្រាក់តាមច្បាប់ទាក់ទងនឹងការបញ្ឈប់ ពីការងារនេះ ។

- នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ក្រុមហ៊ុនបានបើកប្រាក់ខែជូនទៅកម្មការនី ដែលមិនចូលធ្វើការវិញ ដោយបើកទាំងប្រាក់ខែ និង ប្រាក់ឈប់សម្រាកប្រចាំឆ្នាំ និង ប្រមូលយកកាតសំគាល់ខ្លួនវិញ ។
- ក្នុងសវនាការភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមិនបានបញ្ឈប់កម្មករនិយោជិតទាំង ១៣ នាក់នោះពីការងារទេ គឺពួកគាត់មិនព្រមចូលធ្វើការ ចំពោះគោលជំហរក្រុមហ៊ុនគឺនៅតែទទួលឱ្យពួកគាត់ចូលធ្វើការវិញដដែរ ។ នៅក្នុងសវនាការក្រុមហ៊ុននៅតែរក្សាជំហររបស់ខ្លួនថា អ្នកស្រី គ្រិត ស្រីមុំ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើជាប្រធានក្រុមទៀតទេ ហើយក្រុម បេ ក៏លែងត្រូវការឱ្យមានមេក្រុមខ្មែរទៀតហើយដែរ ។
- នៅពេលសព្វថ្ងៃនេះ មានកម្មការនីចំនួន ១៣ នាក់ ដែលមិនព្រមចូលធ្វើការហើយបានធ្វើការទាមទារដូចខាងក្រោមនេះ :

  ១. ទាមទារឱ្យអ្នកស្រីគ្រិតស្រីមុំ បានចូលធ្វើជាប្រធានក្រុមវិញ ទើបកម្មការនីទាំង ១៣ នាក់យល់ព្រម ត្រឡប់ចូល ធ្វើការងារវិញ ព្រោះថា អ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុមល្អ ។
  ២. បើអ្នកស្រី គ្រិត ស្រីមុំ មិនបានចូលធ្វើការវិញក្នុងតួនាទីជាប្រធានក្រុម បេ វិញទេនោះ កម្មការនីទាំង ១៣ នាក់ ទាមទារឱ្យក្រុមហ៊ុនធ្វើការទូទាត់ប្រាក់ទៅតាមច្បាប់ស្តីពីការងារ ព្រោះក្រុមហ៊ុនបានគាបសង្កត់លើ ពួកគាត់ដែលបង្ខំឱ្យពួកគាត់មិនអាចធ្វើការបាន ដូច្នេះការឈប់របស់ពួកគាត់គឺ បណ្តាលមកពីក្រុមហ៊ុន និង ជាការបញ្ឈប់ដោយខុសច្បាប់ ។

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារក្រុមហ៊ុន ឱ្យរក្សាតំណែងអ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម បេ ដដែល**

កម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនរក្សាតួនាទីរបស់អ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម បេ នៅដដែល ។ ដោយឡែកភាគីនិយោជក បានលើកឡើងថា ក្រុមហ៊ុនមិនអាចទទួលអ្នកស្រី គ្រិត ស្រីមុំ ឱ្យជាប្រធានក្រុមបន្តទៅទៀតបានទេ ព្រោះអ្នកស្រីពុំមានសមត្ថភាពធ្វើជាប្រធានក្រុមឡើយ ។ ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើកម្មករនិយោជិតទាំង ១៣ នាក់នោះ មានសិទ្ធិទាមទារឱ្យក្រុមហ៊ុនរក្សា តំណែងអ្នកស្រី គ្រិត ស្រីមុំ ដែរឬទេ?

មាត្រា៦៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ ចែងថា " *កិច្ចសន្យាការងារគឺជា កិច្ចសន្យាដែលបង្កើតឱ្យមានទំនាក់ទំនងការងាររវាងកម្មករនិយោជិត និង និយោជក ។.........* "

មាត្រា២២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ដដែល ចែងថា "*កិច្ចសន្យា គឺទុកជាច្បាប់របស់ភាគី ។ កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមពីគូភាគី ។ កិច្ចសន្យាត្រូវយកទៅអនុវត្ត ដោយសុច្ចរិត និងតាមបំណងរបស់គូភាគី ។ កិច្ចសន្យាមានអនុភាពតែទៅលើភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ។*"

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយថា "*យោងតាមស្មារតីនៃមាត្រា៦៥ នៃច្បាប់ស្តីពីការងារ មាត្រា២២ នៃក្រឹត្យ-ច្បាប់៣៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែភាគីនៃកិច្ចសន្យាទេ ទើបអាចរំលាយ បញ្ចប់ ឬផ្លាស់ប្តូរកិច្ចសន្យានេះបាន ។ ភាគីទីបីមិនអាចបញ្ចប់ ឬទាមទារជំនួសឱ្យភាគីនៃកិច្ចសន្យាបានឡើយ លុះត្រាតែមានការព្រមព្រៀងពីគូភាគីនៃកិច្ចសន្យា ។* " (សូមមើលសេចក្តីបង្គាប់លេខ ***០២/០៥-ប៊ូមីន លេខ៨៨/០៦- ខេមបូឌាអឹបភែរេល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣ និងលេខ ៥០/០៧- អ៊ីម និង វ៉ៃ ទី៣*** ) ។

ក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតចំនួន ១៣ នាក់ ដែលជាភាគីក្រៅកិច្ចសន្យាការងារបានទាមទារឱ្យក្រុមហ៊ុនរក្សាតំណែងអ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម បេ ដដែល។ នៅក្នុងសវនាការ អ្នកស្រី គ្រិត ស្រីមុំ មិនបានផ្តល់ជាអំណះអំណាង ឬហេតុផលណាដើម្បីគាំទ្រថា ការដែលក្រុមហ៊ុនធ្វើការទំលាក់តំណែង របស់គាត់នេះគឺមិនត្រឹមត្រូវ ឬមិនសមហេតុផលនោះទេ ។ ជាក់ស្តែង គឺមានតែកម្មករនិយោជិត ដែលជាភាគីក្រៅកិច្ចសន្យាបានធ្វើការទាមទារថា គាត់ចង់ឱ្យក្រុមហ៊ុនរក្សាតំណែងអ្នកស្រី ដោយហេតុថាគាត់ជាប្រធាន ក្រុមល្អ។ ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីក្រៅកិច្ចសន្យាចំនួន ១៣ នាក់នេះ មិនអាចទាមទារជំនួសឱ្យអ្នកស្រី គ្រិត ស្រីមុំ ដែលជាភាគីនៃកិច្ចសន្យាជាមួយក្រុមហ៊ុន រក្សាតំណែងគាត់ ឱ្យនៅដដែលទេ ពីព្រោះកម្មករនិយោជិតាំងនេះមិនមែនជាភាគីនៃកិច្ចសន្យាទេ ។

លើសពីនេះទៀត មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ចែងថា "*សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះមានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយ ជាប្រាកដ ដូចជាក្នុង រោងចក្រ រោងជាង ការដ្ឋាន ។ល ។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក ។...*"

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ខាងលើនេះ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គិកណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមហេតុផល ។ ***(សូមមើលសេចក្តីបង្គាប់លេខ ៣៩/០៧-សាន សានហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២. លេខ ៥៤/០៧-យ៉ុងភីទី១ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៩. លេខ៤៧/០៨ - ប្រែន ចិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២*** )

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សិទ្ធិចាត់ចែងរបស់ក្រុមហ៊ុនរួមមាន

ការសម្រេចចិត្តក្នុងការតម្លើងឋានៈរបស់កម្មករនិយោជិតណាម្នាក់នៅក្នុងក្រុមហ៊ុន ដើម្បីឱ្យក្រុមហ៊ុនអាចប្រព្រឹត្តទៅ ឬ ដំណើរការបានមានលទ្ធផលល្អ ។

ដោយហេតុថា កម្មករនិយោជិតទាំង ១៣ នាក់នេះ មិនអាចធ្វើការទាមទារជំនួស អ្នកស្រី គ្រិត ស្រីមុំ បានទេ ដូច្នេះដើម្បីឱ្យស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនរក្សាតំណែងរបស់អ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម បេ ឱ្យនៅដដែល ។

**ចំណុចវិវាទទី ២ : បើអ្នកស្រី គ្រិត ស្រីមុំ មិនបានចូលធ្វើការវិញក្នុងតួនាទីជាប្រធានក្រុមបេ វិញទេនោះ កម្មការិនីទាំង ១៣ នាក់ ទាមទារឱ្យក្រុមហ៊ុនធ្វើការទូទាត់ប្រាក់ទៅតាមច្បាប់ស្ដីពីការងារ ព្រោះក្រុមហ៊ុនបានគាបសង្កត់លើពួកគាត់ដែលបង្ខំឱ្យពួកគាត់មិនអាចធ្វើការបាន ដូច្នេះការឈប់របស់ពួកគាត់ គឺបណ្ដាលមកពីក្រុមហ៊ុន និង ជាការបញ្ឈប់ដោយខុសច្បាប់**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណាថា *ការដែលកម្មករនិយោជិតទាំង ១៣ នាក់នេះ ជ្រើសរើសមិនត្រឡប់ចូលធ្វើការ គឺដោយសារមានការគាបសង្កត់ពីនិយោជកដែរឬទេ? តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់បណ្ដេញចេញ និង ជំងឺចិត្តដែរឬទេ?*

យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ក្នុងអំឡុងពេលពី ថ្ងៃទី ២៨ ខែ កុម្ភៈ រហូតដល់ ថ្ងៃទី ១០ ខែ មីនា មានកម្មករនិយោជិតនៅក្រុម បេ មួយចំនួនបានត្រឡប់ចូលធ្វើការវិញ ដោយឡែកមានតែកម្មករនិយោជិតចំនួន ១៣ នាក់ទេ ដែលមិនព្រមចូលធ្វើការដោយដាក់លក្ខខណ្ឌដល់និយោជកឱ្យទទួលយក អ្នកស្រី គ្រិត ស្រីមុំ ចូលធ្វើការវិញ ប៉ុន្តែពួកគាត់បានបើកប្រាក់ឈ្នួលចុងក្រោយ និងប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំហើយ នៅថ្ងៃទី ១០ ខែ មីនា។ កម្មករទាំង ១៣ នាក់ មានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិត ដែលចោទប្រកាន់ថា និយោជកបានធ្វើការគាបសង្កត់ គឺជាភាគីដែលមានបន្ទុកភស្តុតាង ដើម្បីធ្វើការគាំទ្រអំណះអំណាងរបស់ខ្លួន។ (សូមមើលសេចក្ដីបង្គាប់លេខ ***៧៩/០៥-អេវើរហ្គ្រីន.លេខ ៧៧/០៨- ស៊ីង តាយ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី ១ លេខ ១០១/០៨-ជីអ៊ីអ៊ឹម ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី ១ និង ទី២ និងលេខ ១០៨/០៨-ហ៊ូ ហ្គោ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី៤***) ។

នៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា នៅពេលដែលអ្នកស្រី គ្រិត ស្រីមុំ ត្រូវបានប្ដូរតំណែងពីប្រធានក្រុមមកជាកម្មករធម្មតា កម្មករនិយោជិតក្រុម បេ ទាំងអស់មានការមិនសប្បាយចិត្តហើយបានសម្រេចចិត្តមិនធ្វើការ ប៉ុន្តែបន្ទាប់ពីក្រុមហ៊ុនបានប្រកាសឱ្យពួកគាត់ចូលត្រឡប់ចូលធ្វើការវិញ កម្មករភាគច្រើន

បានចូលធ្វើការវិញ លើកលែងតែកម្មករទាំង ១៣ នាក់ (ក្នុងចំណោម ៣៦ នាក់) ដែលនៅតែជ្រើសរើសមិនចូលធ្វើការវិញ។ ភាគីកម្មករបានអះអាងថា ការដែលពួកគាត់ជ្រើសរើសមិនចូលធ្វើការ គឺក្រុមហ៊ុនគាបសង្កត់ពួកគាត់ និង ឱ្យក្រុមហ៊ុនទូទាត់ប្រាក់បញ្ចប់កិច្ចសន្យាតាមច្បាប់ការងារ មាត្រា ៩០ និង ៩១ ។

មាត្រា ៩០ នៃច្បាប់ស្តីពីការងារ " ប្រាក់បំណាច់នៃការបណ្តេញចេញត្រូវតែបើកឱ្យកម្មករនិយោជិត ហើយកម្មករនិយោជិតនោះ ក៏អាចទាមទារជំងឺចិត្តបាន ទោះបីការផ្តាច់កិច្ចសន្យាមិនមែនធ្វើដោយនិយោជកក្តី ក៏ប៉ុន្តែ និយោជកនេះបានជំរុញ ដោយអំពើអាក្រក់របស់ខ្លួនឱ្យឃើញច្បាស់ថា កម្មករនិយោជិតបានផ្តាច់កិច្ចសន្យាដោយខ្លួនឯង។ កាលបើនិយោជកបានប្រើកម្មករនិយោជិតដោយអយុត្តិធម៌ ឬដោយរំលោភញឹកញាប់លើ "ខ"ខ្លះនៃកិច្ចសន្យានេះ ក៏ត្រូវសងប្រាក់បំណាច់ និងជំងឺចិត្តដល់កម្មករនិយោជិតដែរ។"

ក្នុងសវនាការ ក្រៅពីអំណះអំណាងដែលភាគីកម្មករនិយោជិត បានលើកឡើងអំពីការមិនសប្បាយចិត្តរបស់ពួកគាត់ កម្មករនិយោជិតក៏មិនបានបង្ហាញភស្តុតាង ឬ ហេតុផលអ្វីផ្សេងពីនេះដែរ។

យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញ មូលដ្ឋានគ្រប់គ្រាន់ក្នុងការពិចារណាថា ក្រុមហ៊ុនធ្វើការគាបសង្កត់ ឬប្រព្រឹត្តទង្វើអាក្រក់ ឬ កំហុសដូចមានចែងក្នុងមាត្រា ៨៣ (ក) នៃច្បាប់ស្តីពីការងារ មកលើកម្មករនិយោជិតទាំង ១៣ នាក់នេះ ឱ្យឈប់ពីការងារទេ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែបដិសេធការទាមទាររបស់កម្មករនិយោជិតក្នុងករណីគ្មានភស្តុតាងគ្រប់គ្រាន់។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ***៦៣/០៤-សាញូ វីវល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤. លេខ ៧៤/០៧-គួបល អាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ លេខ ៩៤/០៧- ហូរផ្សន ហ្គាមេន ហេតុផល នៃសេចក្តីសម្រេចចំណុចវិវាទទី៦ និង៨ និងលេខ ១០១/០៨-ជីឌីអ៊ីម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទ ទី១ និងទី២ និងលេខ ១០៨/០៨-ហ៊ូ ហ្គេ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤) ។***

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនបានធ្វើការគាបសង្កត់ ឬបង្ខំដោយទង្វើអាក្រក់របស់ខ្លួនឱ្យកម្មករនិយោជិតទាំង ១៣ នាក់នេះ ឈប់ពីការងារទេ តែកម្មករនិយោជិតបានសម្រេចចិត្តជ្រើសរើសឈប់ធ្វើការដោយខ្លួនឯង ដោយសារគ្មានអ្នកស្រី ក្រិត ស្រីមុំ ជាប្រធានក្រុម បេ ទៀត។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យ ក្រុមហ៊ុនធ្វើការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនរក្សាតំណែង របស់ អ្នកស្រី គ្រិត ស្រីមុំ ជាប្រធានក្រុម បេ ឱ្យនៅដដែល។

**ចំណុចវិវាទទី ២ :** បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យ ក្រុមហ៊ុនធ្វើការទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យា។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម តិរម្យ**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **អាំង អេងថុង**

ហត្ថលេខា: ---------------------------------